-ប្រជុំពិភាក្សាត្រៀមខ្លឹមសារពាក់ព័ន្ធ នឹងសហប្រតិបត្តិការតាមព្រំដែន ដើម្បីជួបពិភាក្សាធ្វើការងារជាមួយគណៈប្រតិភូអគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

ប្រការ ៣ : គណៈកម្មការចំរុះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ របស់អនុប្រធានក្នុងករណីប្រធានអវត្តមាន ហើយត្រូវរាយការណ៍លទ្ធផលការងាររបស់ខ្លួនជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

ប្រការ ៤ : គណៈកម្មការចំរុះនេះ នឹងត្រូវរំសាយក្រោយពេលជួបពិភាក្សាជាមួយគណៈប្រតិភូ អគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវបានបញ្ចប់ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៧ សសរ
## ស្តីពីការបង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាកសាងទីក្រុងពិសេសមួយនៅប្រជុំកោះរុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាកសាងក្រុងពិសេសមួយនៅព្រៃជុំកោះរុង ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯ.ឧ សុខ អាន | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២-ឯ.ឧ អ៊ឹម ឈុនលឹម | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៣-ឯ.ឧ ហេង ទឡ្យ៊ីនឆាត | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ជាអនុប្រធាន |
| ៤-ឯ.ឧ អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯ.ឧ ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ៦-ឯ.ឧ ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៧-ឯ.ឧ ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨-ឯ.ឧ ឆាន់ សាផាន់ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| ៩-ឯ.ឧ សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១០-តំណាងក្រុងព្រះសីហនុ | | ជាសមាជិក |

ប្រការ ២ : ក្រុមការងារនេះ មានបេសកកម្មដូចតទៅ ៖

-សិក្សាស្រាវជ្រាវគ្រប់ទិដ្ឋភាព និងវាយតម្លៃអោយបានត្រឹមត្រូវ ដើម្បីលើកគំរោងស្ថាបនាទីក្រុងពិសេសមួយនៅ " ព្រៃជុំកោះរុង " ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើនេះ ក្រុមការងារខាងលើមានសិទ្ធិ និង ភារកិច្ចដូចតទៅ ៖

-គ្រប់សមាជិកទាំងអស់ត្រូវសកម្មចូលរួមប្រជុំការងារតាមសេចក្តីអញ្ជើញរបស់ប្រធាន ដែលនឹងបែងចែកភារកិច្ចជូនអោយទទួលខុសត្រូវតាមមុខជំនាញរៀងៗខ្លួន ។

-ធ្វើទំនាក់ទំនងជាមួយវិនិយោគិនពាក់ព័ន្ធស្ថាប័នជំនាញដែលពាក់ព័ន្ធ សំដៅប្រមូលនូវទិន្នន័យជាមូលដ្ឋាន ។

-ធ្វើការសិក្សាលំអិតអំពីទិដ្ឋភាពច្បាប់ ទិដ្ឋភាពភូមិសាស្ត្រ ទិដ្ឋភាពសេដ្ឋកិច្ច ទិដ្ឋភាពបរិស្ថាន សាគរសាស្ត្រ ជាអាទិ៍ផ្នែកគមនាគមន៍តាមសមុទ្រ និង លទ្ធភាពអំណោចផលចាំប្រទ្ធូវការស្ថាបនាទីក្រុងនេះ ។

-រាយការណ៍អំពីសកម្មភាពជាក់ស្តែងរបស់ក្រុមការងារ ជូនប្រមុខរាជរដ្ឋាភិបាលជ្រាបទាន់ពេលវេលា ។

-រៀបចំផ្នែកជំនាញផ្សេងៗក្នុងករណីចាំបាច់ ដើម្បីសិក្សាប្រមូលទិន្នន័យ ។

-ប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និង

ទីភ្នាក់ងារ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងព្រះសីហនុ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងឯកឧត្តមដែលមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ៥៨ សសរ

## ស្តីពីការតែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

ប្រការ ១ : តែងតាំងលោកឧកញ៉ា ឌូស្ថាន ឃាស្សាន់ ជាទីប្រឹក្សាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : លោកឧកញ៉ា ឌូស្ថាន ឃាស្សាន់ ត្រូវអនុវត្តនូវសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ៥៩ សសរ

## ស្តីពីការផ្ទេរសិទ្ធិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា